**A MADAME AUDREY AZOULAY**
**DIRECTRICE GENERALE DE L'UNESCO**
7, place de Fontenoy
75352 Paris CEDEX 07France

# ញត្តិ
## សហគមន៍ខ្មែរ នៅប្រទេសបារាំង

**ជម្រាបមក** **លោកស្រី អូដ្រេ អាស្ស៊ូឡេ** ( AUDREY AZOULAY )
**អគ្គនាយិកានៃ អង្គការយូណេស្កូ**
**ទីក្រុងប៉ារីស**

**<u>កម្មវត្ថុ ៖ គម្រោងសាងសង់ឧទ្យានកំសាន្តមួយ នៅជិតឧទ្យាអង្គរ ប្រទេសកម្ពុជា</u>**

### លោកស្រីអគ្គនាយិកានៃអង្គការ យូណេស្កូ

ការសាងសង់នាអនាគតនៃឧទ្យានកំសាន្ត «Angkor Lake of Wonder» ដ៏ធំធេងរបស់ក្រុមហ៊ុន កាស៊ីណូ«ណាហ្គាខប (NagaCorp)» លើទីដីទំហំ ៧៥ហិកតារ និងនៅចម្ងាយប្រមាណ ៥០០ ម៉ែត្រប៉ុណ្ណោះពី«ឧទ្យានបុរាណវត្ថុអង្គរ» នឹងធ្វើឲ្យប៉ះពាល់ជាខ្លាំង ដល់បេតិកភណ្ឌវប្បធម៌ និងសិល្បកម្មដ៏សំខាន់បំផុតរបស់ប្រជាជាតិខ្មែរ ដែលត្រូវបានចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោក ប្រឈមនឹងគ្រោះថ្នាក់ នៅថ្ងៃទី ១៤ ធ្នូ ១៩៩២។

ការប៉ះពាល់ធំផុត គឺវត្តមាន និងសកម្មភាពនៃសំណង់ថ្មីនេះ វានឹងធ្វើឲ្យសាបរលាបដល់កិត្តិនាមដ៏ឧត្តុង្គឧត្តម របស់អង្គរ ដែលតំណាងនូវអរិយធម៌ខ្ពង់ខ្ពស់ របស់ប្រជាពលរដ្ឋខ្មែរ ហើយដែលបានផ្តល់កំណើតដំបូងបំផុត នៃប្រជាជាតិខ្មែរ។ ប្រាសាទអង្គរ បានក្លាយជានិមិត្តរូបនៃអត្តិភាព និងជាព្រលឹងនៃប្រជាជាតិខ្មែរនេះ។ ជាអាទិ៍ យើងបានឃើញហើយថា របបនយោបាយខ្មែរ ជាបន្តបន្ទាប់ (ទោះបីរបបបដិវត្តកុម្មុយនីស្ត ដែលប្រាថ្នាកម្ទេចចោលប្រវត្តិសាស្រ្តចាស់ខ្មែរក្តី) បានយករូបភាពប្រាសាទអង្គរវត្ត ដាក់នៅលើទង់ជ័យជាតិ ដូចគ្នាទាំងអស់។

ប្រាសាទអង្គរវត្ត និងប្រាសាទធំ-តូចឯទៀតទាំងអស់ នៃសម័យអង្គរ ក៏មិនមែនជាសំណង់ សម្រាប់សាធារណជនមកមើលកំសាន្ត ឬមកធ្វើបុណ្យទានអ្វីផ្ទាល់ខ្លួនទេ។ ប្រាសាទនីមួយៗនោះ សុទ្ធជាទីសក្ការបូជា ត្បិតជាទីដ្ឋានអាសនៈ នៃព្រះអាទិទេព ឬព្រះពុទ្ធអង្គ និងពពួកទេវតា ដែលថែរក្សា-ការពារមហានគរ និងប្រជាជាតិខ្មែរ។ ហេតុនេះ ទើបមានតែក្រុមសាសនិកធំៗ និងព្រះរាជាប៉ុណ្ណោះ ដែលអាចចូលទៅក្នុងប្រាសាទ ដើម្បីប្រារព្ធពិធីបូជា និងបួងសួងផ្សេងៗ។ រីឯអ្នកឯទៀតទាំងអស់ ចូលរួមពិធីត្រឹមតែនៅជុំវិញប្រាសាទប៉ុណ្ណោះ។ នៅសម័យនេះ ក្រុមអ្នកទេសចរច្រើនលើសលប់ បានពន្លឿនសំណឹកថ្ម នាំឱ្យខូចវិនាសច្រើន ជាជាងនាសតវត្ស៍នៃការបោះបង់អង្គរ នៅកណ្តាលព្រៃ ដូចមានការសង្កេតឃើញរបស់អង្គការយូណេស្កូ ពីឆ្នាំ២០១៣ ស្រាប់ (*Angkor: la rançon d'un succès, UNESCO 20/12/2013*)។ អ្នកឯកទេសអន្តរជាតិ បានទាំងជំទាស់ នឹងការសាងសង់អាកាសយាន្តដ្ឋាន សម្រាប់យន្តហោះធំៗ ដែលបន្លឺស្នូរសម្លេងខ្លាំងៗ នៅជិតបរិវេណនៃអង្គរវត្ត ផង។

ការប៉ះពាល់ធំមួយទៀត គឺដល់សំណង់ប្រាសាទទាំងនោះ ដែលអ្នកឯកទេសថា មិនមានភាពមាំមួនទេ ហើយត្រូវការកិច្ចថែរក្សាជាប្រចាំ ពីព្រោះប្រាសាទត្រូវបានសាងសង់ ដោយគ្មានបុកគ្រឹះជ្រៅ នៅលើទីដីខ្សាច់សើម ជាហេតុធ្វើឲ្យប្រាសាទអង្គរវត្ត ត្រូវការទឹកជាច្រើន ជាអចិន្ត្រៃយ៍ព័ទ្ធជុំវិញ។ ពេលនេះ គេបានសង្កេតឃើញមានស្នាមប្រេះ ដោយអន្លើទៅ

ហើយ។ នេះដោយសារ គ្រឹះស្ថាបនាទន់ជ្រាយ នៅលើទីដីសើម ដែលធ្វើឲ្យប្រាសាទ មិនអាចទប់ទល់ និងការជ្រៀតជ្រែក នៃរុក្ខជាតិ និងកម្លាំងខ្លាំងក្លា នៃការប្រែប្រួលនៃអាកាសធាតុ (ភ្លៀង ព្យុះ រន្ទះ...) ផងបានយូរទេ។ *តើអ្នកឯកទេសអន្តរជាតិទាំងនោះ បានចំណាយពេលវេលាប៉ុន្មានឆ្នាំ ប៉ុន្មានទសវត្សន៍ ដោយមធ្យោបាយមនុស្ស និងធនធានប៉ុន្មាន ដើម្បីគ្រាន់តែធ្វើការជួសជុល ឬការតម្លើង និងសាងសង់ជាថ្មី នូវប្រាសាទ ដែលបានបាក់បែក ឬរលំរលាយរូបនោះ?*

សណ្ឋាគារផ្កាយ៥ ខ្ពស់ៗស្កឹមស្កៃ ២ កន្លែង ជិះក្ការលេងលើទឹក ល្ខោនទឹកខ្នាតធំ សួនបុប្ផាចម្រុះពណ៌ ឧទ្យានបែបវប្បធម៌ប្រវត្តិសាស្ត្រ និង «ទីក្រុងចិន (China Town)» នឹងនាំទេសចរ មកច្រើនជ្រុលទៀតមិនខាន។ អាងទឹកធំធេងរបស់ក្រុមហ៊ុន«ណាហ្គាខប»នោះសោត នឹងត្រូវការទឹកច្រើនលើសលប់ ពីស្ទឹងសៀមរាប ដែលសព្វថ្ងៃនេះ មានការខ្វះខាតទឹកទៅហើយ សម្រាប់ទីក្រុងសៀមរាប និងនៅឧទ្យានអង្គរនោះ។ រីឯទីក្រុងចិន (China Town) របស់ក្រុមហ៊ុននោះ យើងបានឃើញហើយ នៅទីក្រុងភ្នំពេញ និងនៅទីក្រុងព្រះសីហនុ ដូចគ្នានិងការបង្កើត«ឆៃណាថោន» នៅគ្រប់កន្លែងទាំងអស់ក្នុងលោក វាតែងតែជាទីតាំងនៃការផ្សាយវប្បធម៌ចិន យ៉ាងខ្លាំងក្លាបំផុត ដែលធ្វើឲ្យសាបរលាប ឬបាត់ទាំងស្រមោល នូវវប្បធម៌របស់អ្នកម្ចាស់ប្រទេសតែម្តង។

*តើទាំងអស់នេះ មិនមែនជាការលក់គុណបុណ្យដ៏ធំធេងរបស់អង្គរ ឲ្យទៅឈ្មួញរកស៊ី ក្នុងនាមនៃ«អភិវឌ្ឍន៍» ឬទេ? តើគេត្រូវធ្វើកិច្ចអភិវឌ្ឍប្រទេស សម្រាប់តែលុយ និងដើម្បីតែលុយ ឬ?*

សហគមន៍ខ្មែរនៅក្រៅប្រទេស បន្ទាប់ពីបានទទួលដំណឹង គួរឲ្យបារម្ភជាខ្លាំង ចំពោះការសាបរលាបកិត្តិនាម នៃអរិយធម៌ និងវប្បធម៌ដ៏ខ្ពង់ខ្ពស់ ព្រមទាំងនិមិត្តរូបរស់រវើក នៃព្រលឹងរបស់ជាតិខ្មែរ ដោយសារវត្តមាន និងសកម្មភាព នៃឧទ្យានកំសាន្ត របស់ក្រុមហ៊ុន«ណាហ្គាខប»នោះ។

សូមលោកស្រីអគ្គនាយក ដោយយោងតាមសមត្ថកិច្ចដ៏ខ្ពង់ខ្ពស់ នៃអង្គការយូណេស្កូ ក្នុងការថែរក្សាសម្បត្តិបេតិកភណ្ឌពិភពលោក មេត្តាធ្វើអន្តរាគមន៍ ដើម្បីកម្រិតចំនួនទស្សនាចរ នៅប្រាសាទអង្គរ និងបញ្ឈប់ គម្រោងសាងសង់ឧទ្យានកំសាន្តនោះ ដើម្បីជួយសង្គ្រោះអង្គរវត្ត និងដួងព្រលឹងជាតិខ្មែរ ឱ្យរួចអំពីហានិភ័យនេះ។

សូមលោកស្រីអគ្គនាយកា ទទួលនូវសេចក្តីគោរព និងដឹងគុណដ៏ជ្រាលជ្រៅអំពីយើងខ្ញុំ។

ធ្វើនៅប្រទេសបារាំង ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០២០

**សហគមន៍ខ្មែរ នៅប្រទេសបារាំង**

**<u>ចម្លង ថ្វាយ និងជូន៖</u>**

- ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម ប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការយូណេស្កូ